ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៩២១ សសរ

# សេចក្តីសំរេច
## ស្តីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួង
## ដើម្បីរៀបចំខួប ១០ ឆ្នាំ នៃការរស់ឡើងវិញលើវិស័យខ្លែងខ្មែរ
## ថ្ងៃទី ១១-១២-១៣ ខែ ធ្នូ ឆ្នាំ ២០០៤

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- យោងតាមការងារចាំបាច់ចំពោះមុខ

## សំរេច

**ប្រការ ១ :** បង្កើតគណៈកម្មការអន្តរក្រសួងមួយ ដើម្បីរៀបចំខួប ១០ ឆ្នាំ នៃការរស់ឡើងវិញលើវិស័យខ្លែងខ្មែរ ។

**ប្រការ ២ :** សមាសភាពគណៈកម្មការអន្តរក្រសួង មានដូចតទៅ :

| | | | |
|---|---|---|---|
| ១-អ្នកអង្គម្ចាស់ | **ស៊ីសុវត្ថិ ប៉ាណារ៉ា ស៊ីរីវុឌ្ឍ** | រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ប្រធាន |
| ២-ឯកឧត្តម | **យឹម សារិទ្ធ** | រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៣-ឯកឧត្តម | **រស់ ផន** | រដ្ឋលេខាធិការ ក្រសួង ទេសចរណ៍ | អនុប្រធាន |
| ៤-ឯកឧត្តម | **ស៊ូ ស៊ីម** | អនុរដ្ឋលេខាធិការ ក្រសួង ពត៌មាន | សមាជិក |
| ៥-ឯកឧត្តម | **សោម សុគន្ធ** | អនុរដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៦-ឯកឧត្តម | **អ៊ុក សុជាតិ** | អនុរដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |

| | | | |
|---|---|---|---|
| ៧-ឯកឧត្តម | សំរ៉ាំង កំសាន្ត | អនុរដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៨-ឯកឧត្តម | សាយ សុផានិត្យ | អនុរដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៩-ឯកឧត្តម | ឡុយ គៀន | សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ | សមាជិក |
| ១០-ឯកឧត្តម | ស៊ឹម សារ៉ាក់ | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ១១-ឯកឧត្តម | ហង្ស សុត | អគ្គនាយកបច្ចេកទេសវប្បធម៌ | សមាជិក |
| ១២-ឯកឧត្តម | ម៉ិច សារិន | អភិបាលរងរាជធានីភ្នំពេញ | សមាជិក |
| ១៣-លោក ឧត្តមសេនីយ៍ទោ | សួន ឈានលី | ប្រធាននាយកដ្ឋានអង្គរក្ស ក្រសួងមហាផ្ទៃ | សមាជិក |
| ១៤-លោក | ស៊ិន ម៉ុនឡឿន | ប្រធាននាយកដ្ឋានរដ្ឋបាលនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៥-លោក | ជែត សារិន | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ | សមាជិកអចិន្ត្រៃយ៍ |
| ១៦-លោក | ម៉ៅ កេង | ប្រធាននាយកដ្ឋានសិល្បៈទស្សនីយភាព | សមាជិក |

**ប្រការ ៣ :** គណៈកម្មការអន្តរក្រសួង មានភារកិច្ចស្វែងរកចំណូលដើម្បីផ្គត់ផ្គង់ដំណើរការរៀបចំពិធីបង្ហោះខ្លែងអបអរសាទរខួប ១០ ឆ្នាំ នៃការរស់ឡើងវិញវិស័យខ្លែងខ្មែរ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ១១-១២-១៣ ខែ ធ្នូ ឆ្នាំ ២០០៤ ។

**ប្រការ ៤ :**- គណៈកម្មការអន្តរក្រសួង មានសិទ្ធិបង្កើតអនុគណៈកម្មការ និងលេខាធិការជាជំនួយការអោយគណៈកម្មការអន្តរក្រសួង ។

- អនុគណៈកម្មការនិងលេខាធិការត្រូវប្រើប្រាស់មន្ត្រីជំនាញតាមអង្គភាពខ្លួនដោយរៀបចំបញ្ជីឈ្មោះសមាជិកស្នើសុំសេចក្តីសំរេចពីគណៈកម្មការអន្តរក្រសួង ។

**ប្រការ ៥ :**- រាល់ការចំណាយរបស់អនុគណៈកម្មការ និងលេខាធិការ ត្រូវធ្វើគំរោងលំអិត និងសុំសេចក្តីសំរេចពីគណៈ-កម្មការអន្តរក្រសួង ។

**ប្រការ ៦ :**- គណៈកម្មការអន្តរក្រសួង មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

**ប្រការ ៧ :**- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងប្រការ ២ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅរហូតដល់ចប់ពិធី ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៧
- ឯកសារ - កាលប្បវត្តិ